# អនុក្រឹត្យ

# ស្ដីពី

# អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៣៧ អនក្រ.បក

ទទួលពេលម៉ោងទីតាំង
កាលបរិច្ឆេទ 31-7-96
លេខ 2346 ម៉ោង 14h30

# អនុក្រឹត្យ

## ស្តីពី

## អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរ

---

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស_៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស_រកត_១០៩៤_៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស_រកត_១០៩៤_៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស_រកម_ ១៩៦_០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- តាមការយល់ព្រមនៃគណៈរដ្ឋមន្ត្រី

**សម្រេច**

**មាត្រា១** -ត្រូវបានបង្កើតអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ដូចមានគំរូចែងក្នុងឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

**មាត្រា២** .-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ មានសុពលភាព ១០ឆ្នាំ ចាប់ពីថ្ងៃចេញអត្តសញ្ញាណប័ណ្ណនេះ ។

មាត្រា៣ .-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ អាចផ្តល់ជូនបានចំពោះតែ ប្រជាពលរដ្ឋខ្មែរ ទាំងពីរភេទ ដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ ។

មាត្រា៤ .-ក្នុងការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ អាជ្ញាធរមានសមត្ថកិច្ច ត្រូវពិនិត្យ ៖

-សំបុត្រកំណើត ឬ

-សាលក្រមរបស់តុលាការបញ្ជាក់ទទួលស្គាល់ថាជននោះកើតពីឪពុក ឬ ម្តាយ ដែលមានសញ្ជាតិខ្មែរ ឬ

-ព្រះរាជក្រឹត្យប្រកាសទទួលស្គាល់ការសុំទាមទារសញ្ជាតិខ្មែររបស់សាមីជន ឬ

-ព្រះរាជក្រឹត្យប្រកាសទទួលស្គាល់ការសុំចូលសញ្ជាតិខ្មែររបស់សាមីជន ឬ

-ឯកសារ ឬ ភស្តុតាងបញ្ជាក់ថាសាមីជន កើតនៅកម្ពុជា ពីឪពុក ឬ ម្តាយ ដែលកើតនៅកម្ពុជា ឬ

-ឯកសារ ឬ ភស្តុតាងបញ្ជាក់ថាសាមីជនធ្លាប់មានសញ្ជាតិខ្មែរ ឬ

-ឯកសារ ឬ ភស្តុតាងបញ្ជាក់ថាសាមីជន កើតពីឪពុក ឬ ម្តាយមានសញ្ជាតិខ្មែរ ឬ

-ឯកសារណាមួយ ដែលអាចបញ្ជាក់បានថា ជននោះជាប្រជាពលរដ្ឋខ្មែរ ។

ក្នុងការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ មន្ត្រីមានសមត្ថកិច្ច ត្រូវទទួលខុសត្រូវផ្ទាល់ខ្លួន តាមទោសប្បញ្ញត្តិ នៃច្បាប់ស្តីពីសញ្ជាតិ ក្នុងករណីដែលខ្លួនចេញអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរអោយជនណាម្នាក់ដែលពុំមានសញ្ជាតិខ្មែរ ។

មាត្រា៥ .-បែបបទនៃការសុំអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ក្នុងការទទួលស្គាល់ភស្តុតាងបញ្ជាក់អំពីសញ្ជាតិ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃដោយមានការយល់ព្រមពីរាជរដ្ឋាភិបាល ។

មាត្រា៦ .-មានតែ មន្ត្រីដែលមានមុខតំណែង អភិបាលខេត្ត ក្រុង ជាមន្ត្រីមានសមត្ថកិច្ចក្នុងការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ។

មន្ត្រីនេះមិនអាចផ្ទេរ ឬ ប្រគល់សិទ្ធិអំណាចនេះអោយមន្ត្រីម្នាក់ទៀតបានឡើយ ។

មាត្រា៧ .-អ្នកសុំអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ត្រូវបង់អាករ តាមការកំណត់របស់ប្រកាសអន្តរក្រសួងមហាផ្ទៃ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

មាត្រា៨ .-ថ្លៃអាករនេះត្រូវបង់ចូលថវិកាជាតិ ។

បែបបទនៃការប្រមូលអាករនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងមហាផ្ទៃ ។

មាត្រា៩ .-បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា១០ .-សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ⁄សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីមុខងារសាធារណៈ គ្រប់ប្រធានស្ថាប័ន ដែលមានការពាក់ព័ន្ធ ត្រូវទទួលអនុវត្ត អនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហត្ថលេខា និង ចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៦

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

នរោត្តម រណឫទ្ធិ ហ៊ុន សែន

បានចម្លងទូលថ្វាយ និង ជំរាបជូន

សម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី១ និង សម្តេចនាយករដ្ឋមន្ត្រីទី២

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ខេង យូ ហុកគ្រី

<u>កន្លែងទទួល</u>

-ខុទ្ទកាល័យព្រះមហាក្សត្រ

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គនាយកដ្ឋានព្រះបរមរាជវាំង

-ខុទ្ទកាល័យសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី១

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី២

-ដូចមាត្រា១០

-ឯកសារ-កាលប្បវត្តិ

## ឧបសម្ព័ន្ធនៃអនុក្រឹត្យ ស្តីពីការបង្កើតអត្តសញ្ញាណប័ណ្ណ
## សញ្ញាតិខ្មែរ







ក្នុងករណីបាត់ ឬ ខូចត្រូវរាយការណ៍ទៅអាជ្ញាធរមានសមត្ថកិច្ច